២៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

---

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៤៥៤

ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៣

សាលដីកា

លេខ : ១៤៥

ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៤

**ខាងនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម ឃឹម ប៉ុណ្ណ ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

២-លោក ស៊ុន ឪម ជាចៅក្រម

៣-លោក ជីវ កេង ជាចៅក្រម

៤-លោក ប្រាក់ គឹមសាន ជាចៅក្រម

៥-លោក សោម សិរីវឌ្ឍ ជាចៅក្រមរបាយការណ៍

៦-លោក យស់ សូខឿន ជាចៅក្រម

៧-លោក ប៉ែន សាវឿន ជាចៅក្រម

៨-លោក មុំង មុន្នីចរិយា ជាចៅក្រម

៩-លោក យូរ ឧត្តរា ជាចៅក្រម

ក្រឡាបញ្ជី លោកស្រី ទី រ៉ាវី

តំណាងមហាអយ្យការ លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកាលេខ ១៤"គ" ចុះថ្ងៃទី ២៨.០១.២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ០៧ ចុះថ្ងៃទី ០៥.១១.២០០១ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ BENITO ALCIDI "ជាចុងបណ្តឹងសាទុក្ខ"ភេទប្រុស អាយុ៥៧ឆ្នាំ ជាតិ អ៊ីតាលី របររកស៊ី ធ្វើសំណង់ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ KJE₁ ផ្លូវ ៩៤ សង្កាត់ស្រះចក ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ដែលមានឈ្មោះ គង់ អានី ជាតំណាង មានមេធាវីឈ្មោះ ពឹង ធីតា ។

និង ចុងចម្លើយឈ្មោះ ANDRE CALABRO "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ ៤២ឆ្នាំ ជាតិ បារាំង របររកស៊ី ពាណិជ្ជករ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ KJ ផ្លូវលេខ៩៤ វត្តភ្នំ សង្កាត់ស្រះចក ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ដែលមានឈ្មោះ ស គិរីវ័ន ជាតំណាង ។

**ចម្ងល់ចំណុចរឿង** : សុំរំលាយកិច្ចសន្យា

តាមបណ្តឹងសាទុក្ខលេខ ១២០ ចុះថ្ងៃទី ០៣.០៣.២០០៣ របស់ឈ្មោះ ស គីរវ័ន ប្តឹងមិនសុខចិត្ត ពីសាលដីកាលេខ ១៤"គ" ចុះថ្ងៃទី ២៨.០១.២០០៣ របស់សាលាឧទ្ធរណ៍ លើចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៤៥៤ ចុះថ្ងៃទី ២៦.១១.២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៦.៥.១៩៩៧ របស់ឈ្មោះ BENITO ALCIDI ប្តឹងសុំរំលាយកិច្ចសន្យា ពីឈ្មោះ ANDRE CALABRO ដោយសំអាងហេតុថា ឈ្មោះនេះ មិនព្រមបង់ថ្លៃឈ្នួលផ្ទះ និងសំភារៈ ដែលបានជួល ចាប់តាំងពីថ្ងៃទី ១៥.៩.១៩៩៦ មក ដោយមានតម្លៃ ៦០០$ ក្នុង១ខែ និងសុំទាមទារយកផ្ទះមកវិញ ដើម្បីរកស៊ីលក់ម្ហូបដោយខ្លួនឯងវិញ ។

បានឃើញសាលក្រមលេខ ៣៦"ជ" ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២៦.៥.១៩៩៧ របស់ដើមចោទឈ្មោះ BENITO ALCIDI ទុកជាត្រឹមត្រូវ តាមទំរង់ច្បាប់ តែបដិសេធចំណុចខ្លះ ដែលផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់កិច្ចសន្យាជួលភោជនីយដ្ឋាន ឡឺដូវិល ចុះថ្ងៃទី ១៥.៩.១៩៩៦ រវាងឈ្មោះ BENITO ALCIDI និង ឈ្មោះ ANDRE CALABRO ទុកជាបានការតាមច្បាប់តទៅ រហូតកំណត់ត្រឹមខែ ៦ ឆ្នាំ ២០០០ ទើបកិច្ចសន្យានេះត្រូវបញ្ចប់ ។

៣-បង្គាប់ឱ្យឈ្មោះ BENITO ALCIDI ប្រគល់ប្រាក់ ១.២០០ដុល្លាអាមេរិក ឱ្យទៅឈ្មោះ ANDRE CALABRO ចាប់ពីថ្ងៃសាលក្រមស្ថាពរ ។

៤-នៅពេលបញ្ចប់កិច្ចសន្យាជួល ភោជនីយដ្ឋាន ក្នុងខែ ៦ ឆ្នាំ ២០០០ បង្គាប់ឱ្យឈ្មោះ ANDRE CALABRO ប្រគល់សំភារៈក្នុងភោជនីយដ្ឋាន នេះ តាមកំណត់ហេតុ កត់ត្រាទ្រព្យសម្បត្តិ ចុះថ្ងៃទី ២២.៧.១៩៩៧ របស់តុលាការក្រុងភ្នំពេញ ឱ្យទៅឈ្មោះ BENITO ALCIDI វិញ ។

៥-បង្គាប់ឱ្យឈ្មោះ ANDRE CALABRO បង់ប្រាក់ប្រដាប់ក្តី ចំនួន ៧.០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០៛ ដែលដើមចោទ បានបង់ទុករួចជាស្រេច ។ កាលបើផុតកំណត់ប្តឹងឧទ្ធរណ៍ ឱ្យឈ្មោះ ANDRE CALABRO សងប្រាក់ ៧.០០០៛ ទៅដើមចោទវិញ និងឱ្យបង់ពន្ធសមាមាត្រ ១%លើប្រាក់១.២០០ ដុល្លាអាមេរិក គឺ ស្មើនឹង ១២ ដុល្លាអាមេរិក ប្រាក់នេះត្រូវបង់ចូលថវិកាជាតិ ៨០% និង រង្វាន់

ក្រឡាបញ្ជីទូទាំងប្រទេស ២០% ។

៦-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខគូភាគី សំរេចបើកផ្លូវប្តឹងឧទ្ធរណ៍ រយៈពេលពីរខែ ចាប់ពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍ របស់ឈ្មោះ គង់ អានី ចុះថ្ងៃទី ០៨.០១.១៩៩៩ ប្តឹងមិនសុខចិត្ត លើសេចក្តីសំរេច នៃសាលក្រមទាំងមូល ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ ៦០១ ចុះថ្ងៃទី ២៤.៨.១៩៩៩ ដែលមាន ខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ របស់អ្នកស្រី គង់ អានី ចុះថ្ងៃទី ០៨.០១.១៩៩៩ ទុកជាត្រឹមត្រូវ តាមទំរង់ និងគតិច្បាប់ ។

២-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ របស់ដើមបណ្តឹងឧទ្ធរណ៍ ទៅឱ្យមេធាវី លឹម ចន្ទ័ប៊ុនកែវ ចុះថ្ងៃទី ១៤.៦.១៩៩៩ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

៣-បដិសេធសាលក្រមលេខ ៣៦ (ជ) ចុះថ្ងៃទី ០២.១២.១៩៩៨ របស់តុលាការ ក្រុងភ្នំពេញ ចោលជាអសារបង់ ។

៤-រំលាយកិច្ចសន្យាជួល ភោជនីយដ្ឋាន ឡឺដូវិល ចុះថ្ងៃទី ១៥.៩.១៩៩៦ រវាងឈ្មោះ BENITO ALCIDI និង ឈ្មោះ ANDRE CALABRO ចាប់ពីពេលនេះតទៅ ។

៥-បង្គាប់ឱ្យឈ្មោះ ANDRE CALABRO ប្រគល់ប្រាក់ចំនួន ១.៨០០ ដុល្លាអាមេរិក "មួយពាន់ប្រាំបីរយដុល្លាអាមេរិក" ជាថ្លៃឈ្នួលផ្ទះ ទៅឱ្យឈ្មោះ BENITO ALCIDI និង ប្រពន្ធឈ្មោះ គង់ អានី ។

៦-បង្គាប់ឱ្យឈ្មោះ ANDRE CALABRO សងថ្លៃខាតបង់សំភារៈ សោហ៊ុយខាតបង់ និង ជំងឺចិត្តទៅឱ្យ BENITO ALCIDI និងប្រពន្ធឈ្មោះ គង់ អានី ចំនួន ១០.០០០ដុល្លាអាមេរិក "មួយម៉ឺនដុល្លាអាមេរិក" ។ សំណូមពរលើសពីនេះ បដិសេធចោល ។

៧-កាត់យកប្រាក់ប្រដាប់ក្តី ជាន់សាលាឧទ្ធរណ៍ ចំនួន ១៣.០០០៛ ដែលដើមបណ្តឹង ឧទ្ធរណ៍បានបង់ទុករួច គឺពន្ធចុះបញ្ជីក្តី និងពន្ធហ៊្វីង ២.៥៥០៛ វង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយ ក្នុងកិច្ចប្រគល់ដីកាកោះ ៥.០០០៛ និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០៛ ។

កាលបើផុតកំណត់ប្តឹងសាទុក្ខ បង្គាប់ឱ្យឈ្មោះ ANDRE CALABRO សងប្រាក់ចំនួន ១៣.០០០៛ ទៅឱ្យដើមបណ្តឹងឧទ្ធរណ៍វិញ និងបង្គាប់ឱ្យឈ្មោះ ANDRE CALARBO បង់ពន្ធសមាមាត្រ

មួយភាគរយលើប្រាក់ ដែលតុលាការបានសំរេចក្នុងចំណុច ទី ៥ និងចំណុច ទី ៦ នៃសេចក្ដីសំរេចនេះ ។ ប្រាក់ពន្ធនេះ ៨០% ត្រូវបានជាប្រយោជន៍ថវិការដ្ឋ និង ២០% ត្រូវបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

៨-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខមេធាវីដើមបណ្ដឹងឧទ្ធរណ៍ និងដើមបណ្ដឹងឧទ្ធរណ៍ កំបាំងមុខចុងបណ្ដឹងឧទ្ធរណ៍ បើកផ្លូវតវ៉ា ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់របស់ឈ្មោះ ANDRE CALABRO ចុះថ្ងៃទី ០៦.៩.១៩៩៩ ប្ដឹងមិនសុខចិត្ត លើសេចក្ដីសំរេច នៃ សាលដីកាកំបាំងមុខលេខ ៦០១ ចុះថ្ងៃទី ២៤.៨.១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ ៧៧១ ចុះថ្ងៃទី ២១.១០.១៩៩៩ ដែលមានខ្លឹមសារនៃ សេចក្ដីសំរេចដូចតទៅ :

១-ទទួលបណ្ដឹងទាស់ចុះថ្ងៃទី ០៦.៩.១៩៩៩ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីកាលេខ ៦០១ ចុះថ្ងៃទី ២៤.៨.១៩៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយជាដើមបណ្ដឹងទាស់ ទុកជាចំពោះមុខ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខ របស់ ឈ្មោះ ANDRE CALABRO ចុះថ្ងៃទី ១៣.១២.១៩៩៩ ប្ដឹងមិនសុខចិត្តលើសេចក្ដីសំរេច នៃសាលដីកាទាំងមូល ។

បានឃើញបណ្ដឹងសាទុក្ខ របស់ឈ្មោះ គង់ អានី ចុះថ្ងៃទី ១៤.១២.១៩៩៩ ប្ដឹងមិនសុខចិត្តត្រង់ចំណុចទី ៥ នៃសាលដីកាទាំងមូល ។

បានឃើញសាលដីការបស់តុលាការកំពូលលេខ ៥៥ ចុះថ្ងៃទី ០៣.៤.២០០១ ដែលមានខ្លឹមសារនៃ សេចក្ដីសំរេចដូចតទៅ :

១-ទទួលបណ្ដឹងសាទុក្ខលេខ ៩៤៧ ចុះថ្ងៃទី ១៣.១២.១៩៩៩. របស់លោក ANDRE CALABRO ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទទួលបណ្ដឹងសាទុក្ខ លេខ ៩៤៨ ចុះថ្ងៃទី ១៤.១២.១៩៩៩ របស់អ្នកស្រី គង់ អានី ទុកជាត្រឹមត្រូវ តាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

៣-ទុកជាមោឃៈ សាលដីការដ្ឋប្បវេណីលេខ ៧៧១ ចុះថ្ងៃទី ២១.១០.១៩៩៩ របស់

សាលាឧទ្ធរណ៍ទាំងមូល ។

៤-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៦១ ចុះថ្ងៃទី ០៣.០២.២០០០ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៥-រិបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលអ្នកស្រី គង់ អានី បានបង់រួចហើយគឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្លឹង ចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ។

បង្វិលប្រាក់ចំនួន ១៩.០០០៛ ទៀត ឱ្យទៅលោក ANDRE CALABRO វិញ ។

៦-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០០១ ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ ១៤ (គ) ចុះថ្ងៃទី ២៨.០១.២០០៣ ដែលមាន ខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១-ទទួលជំនុំជំរះ សំណុំរឿងរដ្ឋប្បវេណី លេខ ៦៧ ចុះថ្ងៃទី ០៥.១១.២០០១ របស់សាលាឧទ្ធរណ៍ ដោយអំណាចសាលដីការដ្ឋប្បវេណីលេខ ៩៥ ចុះថ្ងៃទី ០៣.៤.២០០១ របស់តុលាការកំពូល ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ៣៦ (ជ) ចុះថ្ងៃទី ០២.១២.១៩៩៨ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៣-រំលាយកិច្ចសន្យាជួលភោជនីយដ្ឋាន ឡឺជូវីល ចុះថ្ងៃទី ១៥.៩.១៩៩៦ រវាងឈ្មោះ ANDRE CALABRO និង ឈ្មោះ BENITO ALCIDI ចាប់ពីពេលនេះតទៅ ។

៤-បង្គាប់ឱ្យចុងចម្លើយឈ្មោះ ANDRE CALABRO សងថ្លៃឈ្នួល ជួលភោជនីយដ្ឋានចំនួន ១.២០០ ដុល្លារអាមេរិក (មួយពាន់ពីររយដុល្លារអាមេរិក) និងសងថ្លៃខាតបង់សំភារៈ សោហ៊ុយខាតបង់ផ្សេងៗ និងជំងឺចិត្តសរុបចំនួន ១០.០០០ ដុល្លារអាមេរិក (មួយម៉ឺនដុល្លារអាមេរិក) ឱ្យទៅឈ្មោះ BENITO ALCIDI និងប្រពន្ធឈ្មោះ គង់ អានី ចាប់ពីពេលដែលសាលដីកានេះចូលជាស្ថាពរ ។ សំណូមពរលើសពីនេះ បដិសេធចោល ។

-បើគ្មានប្រាក់សងទេ ត្រូវរឹបអូសទ្រព្យសម្បត្តិ លក់ឡាយឡុងដើម្បីធានាសំណង ។ បើរឹងរូស ត្រូវដាក់គុកបង្ខំរូបកាយ តាមច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៥-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្លឹងចំនួន ២.៩៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៩០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០៛

និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០រៀលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ និងបង្គាប់ឱ្យចុងចម្លើយឈ្មោះ ANDRE CALABRO បង់ពន្ធសមាមាត្រ ១% លើប្រាក់ដែលត្រូវសង ក្នុងចំណុចទី ៤ ។

៦-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្តី ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១២០ ចុះថ្ងៃទី ០៣.៣.២០០៣ របស់ឈ្មោះ ស គិរីវ័ន ( តំណាងឱ្យឈ្មោះ ANDRE CALABRO ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

ម្ចាស់បណ្តឹងសាទុក្ខពុំបានធ្វើសារណាការពារផលប្រយោជន៍ របស់ខ្លួនទេ ។

បានឃើញសារណាបំភ្លឺ របស់ឈ្មោះ គង់ អានី ចុះថ្ងៃទី ២០.០២.២០០៤ ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់ សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អមតុលាការកំពូលថា :

-បណ្តឹងសាទុក្ខរបស់ ចុងចម្លើយ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

-សាលដីការបស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ សូមក្រុមប្រឹក្សាជំនុំជំរះ ពិនិត្យ និងសំរេច ។

បានស្តាប់ចម្លើយឈ្មោះ ស គិរីវ័ន ( តំណាងឱ្យឈ្មោះ ANDRE CALABRO ) ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះឆ្លើយថា :

-ខ្លួនសុខចិត្តសងចំនួន ១.២០០ដុល្លាអាមេរិក ជាថ្លៃជួលផ្ទះ ចំពោះជំងឺចិត្តមួយម៉ឺនដុល្លាអាមេរិក ខ្លួនមិនសុខចិត្តទេ ។ ក្នុងកិច្ចសន្យាជួល គឺជួលជាន់ក្រោមមិនមែនជួលផ្ទះផ្សេង ជួលសំភារៈផ្សេងទេ កាលខ្លួនជួល ជាន់ខាងលើមានហើយ គាត់ជួលពីម្ចាស់ផ្ទះ ទាំងលើទាំងក្រោម ៦០០ ដុល្លាអាមេរិក ហើយគាត់នៅខាងលើ ។ ចំពោះសំភារៈរបស់គាត់ កាលគាត់នៅខាងលើ ខ្លួនជួលផ្ទះគេ ដាក់សំភារៈទាំងនោះ ដល់ឥឡូវខ្លួនយកមកដាក់ នៅជាន់លើវិញ ។ កាលនៅតុលាការក្រុង ខ្លួនសុខចិត្តឱ្យគាត់ ៤ ពាន់ដុល្លាអាមេរិក ដើម្បីបញ្ចប់ទំនាស់ តែគាត់មិនព្រម ហើយគាត់ប្តឹងរហូតមកដល់លើ ដូច្នេះចំពោះ ៤ ពាន់ដុល្លាអាមេរិកនេះ ខ្លួនឈប់ឱ្យហើយ ។

បានស្តាប់ចម្លើយ របស់ឈ្មោះ គង់ អានី ( តំណាងឱ្យឈ្មោះ BENITO ALCIDI ) ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះឆ្លើយ ថា :

-ខ្លួនសុខចិត្ត តាមការសំរេច របស់សាលាឧទ្ធរណ៍ ព្រោះផ្ទះនេះខ្លួនជួលពីគេ មានតែជាន់ក្រោម ក្នុងតម្លៃ ៦០០ ដុល្លាអាមេរិក ហើយខ្លួនក៏សង់ជាន់លើបន្ថែមទៀត និងបំពាក់សំភារៈផ្សេងទៀត

ដើម្បីឱ្យក្លាយជាភោជនីយដ្ឋាន អស់លុយចំនួន ៥ម៉ឺនដុល្លារអាមេរិក ។ កិច្ចសន្យាជួលមានពីរ គឺជួលផ្ទះ និងជួលសំភារៈ ដល់គាត់ស៊ីញ៉េតែ១ ហើយគេចទៅបារាំងបាត់ ។ ក្នុងការជួលនេះគាត់មិនឱ្យឈ្នួលផ្ទះ ខ្លួនប្តឹង គាត់ថាចាំមកពីបារាំងវិញ មកវិញនៅតែមិនឱ្យ ខ្លួនប្តឹងដល់តុលាការ ទើបគាត់ឱ្យទៅម្ចាស់ផ្ទះ ។ ចំពោះសំភារៈរបស់ខ្លួន គាត់នៅតែប្រើរហូតដល់សព្វថ្ងៃ គាត់មិនប្រើតែរបស់ណា ដែលប្រើលែងកើត ។ សុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ ។

មេធាវីរបស់ដើមចោទ ធ្វើសេចក្តីសន្និដ្ឋាន ថា :

-កូនក្តីខ្លួនជួលផ្ទះពីគេ ក្នុងតម្លៃ ៦០០ ដុល្លារអាមេរិក ក្នុង១ខែ ហើយសង់បន្ថែម និងទិញសំភារៈ ដើម្បីឱ្យក្លាយទៅជាភោជនីយដ្ឋាន អស់លុយចំនួន ៥ ម៉ឺនដុល្លារអាមេរិក តើមានប្រយោជន៍អីជួលឱ្យចុងចម្លើយក្នុងតម្លៃដដែល មានសំភារៈប្រើប្រាស់ទៀត ហើយសំភារៈទាំងនេះ ប្រើប្រាស់តាំងពីជួលរហូតមកដល់សព្វថ្ងៃ មានការសឹករិចរិលអស់ ពុំបានថ្លៃឈ្នួល ។ ប្រសិនបើនៅក្នុងកិច្ចសន្យា ពុំមានបង្កប់នយ័អ្វីទេ ក៏ចុងចម្លើយពុំសុខចិត្តសង ៤ពាន់ដុល្លាដែរ ។ សុំតំកល់សាលដីការបស់សាលាឧទ្ធរណ៍ ។

-ក្រោយពីបានស្តាប់ របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ ចម្លើយរបស់គូភាគី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមចោទ

-ក្រោយពីបាន ពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១២០ ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ ២០០៣ របស់លោក ស គីរីវន័ តំណាងឱ្យលោក ANDRE CALABRO ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបាន ដោយយោងតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា ២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលអាចអនុវត្តបាន ក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

-យល់ឃើញថា នៅពេលសវនាការនេះ គូភាគីបានឯកភាពគ្នាថា ចុងចម្លើយពុំទាន់បានបង់ប្រាក់ថ្លៃឈ្នួល ភោជនីយដ្ឋាន ចំនួនពីរខែ ស្មើនឹង ១.២០០ ដុល្លាអាមេរិក មែន ។

-យល់ឃើញថា ពុំមានភស្តុតាងណាបញ្ជាក់ថាចុងចម្លើយត្រូវជួលសំភារៈក្នុងភោជនីយដ្ឋាន ដោយឡែក ពីកិច្ចសន្យាជួលភោជនីយដ្ឋាន ចុះថ្ងៃទី ១៥.៩.១៩៩៦ ទេ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ សំរេចឱ្យចុងចម្លើយ សងប្រាក់ថ្លៃខាតបង់សំភារៈ

សោហ៊ុយបង់ខាតផ្សេងៗ និងជំងឺចិត្ត សរុបចំនួន ១០.០០០ ដុល្លាអាមេរិក ទៅដើមចោទ ដោយអាងហេតុថា ចុងចម្លើយបានប្រើប្រាស់នូវសំភារៈ ដែលដើមចោទបានទិញបំពាក់ធ្វើជាភោជនីយដ្ឋាននេះ អស់រយៈពេល ជាងពីរឆ្នាំ មកហើយនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះតាមកិច្ចសន្យា ចុះថ្ងៃទី ១៥.៩.១៩៩៦ បញ្ជាក់ថា ជួលភោជនីយដ្ឋាន បានន័យថា ជួលទាំងផ្ទះ ទាំងសំភារៈផង ទើបអាចហៅថា ភោជនីយដ្ឋាន ។ ដូច្នេះ មិនអាចគិតថ្លៃ សំភារៈបន្ថែមលើថ្លៃឈ្នួលទៀតទេ ។

-យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់ថា ចុងចម្លើយពុំបានបង់ ថ្លៃឈ្នួលផ្ទះ ឱ្យដើមចោទ ចំនួនពីរខែ ប្រាកដមែន ដូច្នេះចុងចម្លើយ គប្បីផ្តល់ប្រាក់ ជំងឺចិត្តចំនួន ១.០០០ដុល្លាអាមេរិក ឱ្យដើមចោទ ។

-យល់ឃើញថា សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីជាថ្មីឡើងវិញ ពុំបានសំរេចអំពី សំភារៈ ដែលបានកត់ត្រាទុក តាមកំណត់ហេតុ ចុះថ្ងៃទី ២២.៧.១៩៩៧ ទេ តុលាការកំពូល គប្បីសំរេច ប្រគល់ឱ្យដើមចោទ ។

-យល់ឃើញថា សាលដីកាវិនិច្ឆ័យលេខ ១៤ (ត) ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវ ទាំងទំរង់ ទាំងអង្គច្បាប់ហើយ លើកលែងតែប្រាក់សំណង ជំងឺចិត្ត ដែលត្រូវទុកជាមោឃៈ និង សំរេចជាថ្មី ។

**ហេតុដូច្នេះ**

វិនិច្ឆ័យសេចក្តី ចំពោះមុខ គូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ១២០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៣ របស់លោក ស គីរីរ័ន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងអង្គច្បាប់ខ្លះ ។

២-តម្កល់សាលដីកាវិនិច្ឆ័យលេខ ១៤ (ត) ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៣ របស់ សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែប្រាក់សំណងជំងឺចិត្តចំនួន ១០.០០០ ដុល្លាអាមេរិក ដែលត្រូវ ទុកជាមោឃៈ ។

៣-បង្គាប់ឱ្យលោក ANDRE CALABRO សងប្រាក់ជំងឺចិត្ត ចំនួន ១.០០០ ដុល្លាអាមេរិក (មួយពាន់គត់) និង ប្រគល់សំភារៈ ដែលបានកត់ត្រាទុក តាមកំណត់ហេតុ ចុះថ្ងៃទី ២២.៧.១៩៩៧ ឱ្យ ដើមចោទ ។ ករណីដែលមានការបាត់បង់ ឬ ខូចខាត ចុងចម្លើយត្រូវសងដើមចោទ នូវតម្លៃសំភារៈ ទាំងនោះ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តី ចំនួន ១៥.០០០៛ ដែលលោក ANDRE CALABRO បានបង់ ទុកនៅតុលាការកំពូល គឺ ៖

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹង ចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ។

បង្គាប់ឱ្យលោក ANDRE CALABRO បង់ពន្ធសមាមាត្រ ១% លើប្រាក់ដែលត្រូវសងដើមចោទ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ២០០៤ ។